# សុន្ទរកថា
# របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងពិធី "ទស្សនកិច្ចនិងសម្ពោធសមិទ្ធផលនៅអគារអនុវត្តមុខងារសេសសល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)"

អគារអនុវត្តមុខងារសេសសល់របស់ អ.វ.ត.ក., ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០២៤

- *ឯកឧត្តម **វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងប្រធានក្រុមការងាររាជរដ្ឋាភិបាលទទួលបន្ទុកដំណើរការអនុវត្តមុខងារសេសសល់របស់អ.វ.ត.ក.*
- *ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី*
- *ឯកឧត្តម **មីហ្គែល ឌឺ សែប៉ា សូរ៉ារែស** (Miguel de Serpa Soares) អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងជាទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ*
- *ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា*
- *ឯកឧត្តម **ចូហ្សេប ស្វយអឺរ** (Joseph SCHEUER) អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា*
- *ឯកឧត្តម **ហែម ក្រាញ់តូនី** រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានរដ្ឋបាលស្ដីទីនៃ អ.វ.ត.ក.*
- *ឯកឧត្តម **ឃ្នុត រ៉ូសែនហ៊ក** (Knut ROSANDHAUG) អ្នកសម្របសម្រួលកាតព្វកិច្ចអន្តរជាតិនៃ អ.វ.ត.ក.*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាទីគោរពរាប់អាន!*

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សជាអនេក ដែលបានមកចូលរួម និង ថ្លែងសុន្ទរកថា ក្នុងពិធី **"ទស្សនកិច្ចនិងសម្ពោធសមិទ្ធផលនៅអគារអនុវត្តមុខងារសេសសល់របស់ អ.វ.ត.ក."**

ដែលត្រូវបានរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី និង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជាបឋម, ខ្ញុំសូមអរគុណចំពោះគំនិតផ្តួចផ្តើមដ៏ថ្លៃថ្លា ក្នុងការលើកកម្ពស់ការអប់រំផ្សព្វផ្សាយនូវសមិទ្ធផលជាប្រវត្តិសាស្ត្រ ដែលអ.វ.ត.ក. សម្រេចបានកន្លងមក ដល់សិស្សនិស្សិត ជនរងគ្រោះ អ្នកស្រាវជ្រាវ និងមនុស្សជាតិទាំងមូល ដើម្បីចូលរួមចំណែករក្សាសន្តិភាព និងទប់ស្កាត់ការវិលត្រឡប់មកវិញនូវរបបឃោរឃៅខ្មែរក្រហម លើទឹកដីកម្ពុជាម្តងទៀត ហើយវត្តមានរបស់យើងនៅថ្ងៃនេះ ក៏ជាការបង្ហាញពីការទទួលស្គាល់នូវសារៈសំខាន់នៃសមិទ្ធផលជាប្រវត្តិសាស្ត្រនេះផងដែរ។

ខ្ញុំសូមឆ្លៀតយកឱកាសដ៏កម្រនេះ សូមសំដែងនូវការគោរពអរគុណជឹងគុណយ៉ាងជ្រាលជ្រៅបំផុត និងសូមចងចាំជានិច្ចចំពោះស្នាដៃ និងគុណូបការៈដ៏ធំធេងមិនអាចកាត់ថ្លៃបានរបស់ថ្នាក់ដឹកនាំ ជាពិសេសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានរំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ប៉ុលពត និងបាននាំមកនូវសុខសន្តិភាព, ការបង្រួបបង្រួមជាតិ, ឯកភាពជាតិ និងឯកភាពទឹកដី ក្នុងប្រវត្តិសាស្ត្រ ៥០០ ឆ្នាំរបស់ខ្លួន តាមរយៈការដាក់ចេញនូវនយោបាយ **ឈ្នះ-ឈ្នះ** ក៏ដូចជាការប្តេជ្ញាចិត្តខ្ពស់និងការឧបត្ថម្ភគាំទ្ររបស់ **សម្តេចតេជោ** ចាប់តាំងពីគំនិតផ្តួចផ្តើមក្នុងការបង្កើតតុលាការនេះ រហូតដល់បានបញ្ចប់ទាំងស្រុងនូវដំណើរការកាត់សេចក្តីប្រកបទៅដោយរលូន និងមានការទទួលស្គាល់ជាអន្តរជាតិ។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណ និងរម្លឹកផងដែរនូវស្នាដៃ ការលះបង់ និងកេរដំណែលរបស់សម្តេចវិបុលបញ្ញា **សុខ អាន** ដែលបានដឹកនាំក្រុមការងារចរចារបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយសមភាគីចចាររបស់អង្គការសហប្រជាជាតិ ក្នុងការបង្កើតតុលាការកូនកាត់មួយនេះ និងបានដំណើរការទៅដោយរលូន ព្រមទាំងរក្សាបាននូវអធិបតេយ្យភាព និងភាពម្ចាស់ការក្នុងដឹកនាំនិងចាត់ចែងដំណើរការកាត់សេចក្តី។

*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

សន្តិភាព និងសង្គ្រាម តំណាងឱ្យទិដ្ឋភាពពីរ នៃរបៀបដែលយើងប្រាថ្នាចង់រស់នៅជាសង្គមមួយ និងរបៀប ដែលយើងដោះស្រាយនូវភាពខុសគ្នារបស់យើង។ សន្តិភាព និងសង្គ្រាមជាស្ថានភាពដ៏ស្មុគស្មាញបំផុត ដែលមនុស្សគ្រប់រូបនឹងត្រូវប្រឈមមុខ មិនថាជាជនរងគ្រោះនៃសង្គ្រាម ឬជាអ្នកនយោបាយនោះទេ គឺចង់បានការបញ្ចប់ជំលោះ និងកសាងសន្តិភាព។ នយោបាយឈ្នះ-ឈ្នះ គឺជាមូលដ្ឋានគ្រឹះនៃការរក្សាសន្តិភាពយូរអង្វែង ដោយហេតុថានយោបាយឈ្នះ-ឈ្នះនេះ បានលុបបំបាត់ការរើសអើងខាងជាតិសាសន៍ សាសនា និងវាំងក្រុម

មនុស្ស ព្រមទាំងបានផ្តល់លទ្ធភាពដល់ពលរដ្ឋខ្មែរទាំងអស់រួមរស់សុខដុមរមនាក្នុងសង្គមជាមួយគ្នាថែមទៀតផង។ ជាងនេះទៅទៀត តាមរយៈនយោបាយឈ្នះ-ឈ្នះនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបង្កើត អ.វ.ត.ក. ដោយមានកិច្ចសហការដ៏ល្អប្រសើរពីអង្គការសហប្រជាជាតិ និងការឧបត្ថម្ភគាំទ្រជាថវិកាពីសហគមន៍អន្តរជាតិ ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម, ការផ្សះផ្សាសង្គមដែលបែកបាក់, ការលុបបំបាត់វប្បធម៌និទណ្ឌភាព, និងជាការផ្តល់សារមួយសម្រាប់មេដឹកនាំ នៃបណ្តាប្រទេសទូទាំងពិភពលោកអំពីផលវិបាកនៃការប្រព្រឹត្តអំពើសាហាវយង់ឃ្នងព្រៃផ្សៃរបស់ពួកគេ។

ដូចបានគូសបញ្ជាក់នៅក្នុងរបាយការណ៍របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាល ទទួលបន្ទុកដំណើរការអនុវត្តមុខងារសេសសល់របស់ អ.វ.ត.ក. រួចហើយ អ.វ.ត.ក. សម្រេចបានជោគជ័យជាប្រវត្តិសាស្ត្រនឹកស្មានមិនដល់ និងគួរឱ្យកត់សំគាល់ក្រៃលែង ដែលបាននាំយកប្រមុខរដ្ឋនៃរបបមួយមកធ្វើការជំនុំជម្រះទោស, បានលាតត្រដាងនូវការពិតជាប្រវត្តិសាស្ត្រអំពីរបបខ្មែរក្រហម, និងបានផ្តល់យុត្តិធម៌និងជួយសម្រាលផ្លូវចិត្តដល់ជនរងគ្រោះ ព្រមទាំងបានបន្សល់ទុកនូវឯកសារសំណុំរឿងចំនួនជាង ២,៤ លានទំព័រជាភាសាខ្មែរ អង់គ្លេស និងបារាំង។ ឆ្លៀតក្នុងឱកាសនេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងជ្រាលជ្រៅជូនចំពោះអ្នកទាំងឡាយ ដែលបានចូលរួមចំណែកនៅក្នុងដំណើរការនេះ រួមមាន ចៅក្រម ព្រះរាជអាជ្ញា មេធាវី មន្ត្រីច្បាប់ និងមន្ត្រីបុគ្គលិករដ្ឋបាលតុលាការទាំងអស់ទាំងភាគីជាតិ និងអន្តរជាតិ។ ជាពិសេស ខ្ញុំសូមកោតសរសើរនិងថ្លែងអំណរគុណដល់ជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបានផ្តល់សក្ខីកម្មអំពីរឿងរ៉ាវផ្ទាល់ខ្លួនដ៏ជូរចត់នៅចំពោះមុខតុលាការ ដើម្បីស្វែងរកការពិតនិងយុត្តិធម៌ដល់ជនរងគ្រោះទាំងអស់នៃរបបដ៏ឃោរឃៅខ្មែរក្រហម។

មុននឹងចូលរួមកម្មវិធីនេះបន្តិច ខ្ញុំនិងថ្នាក់ដឹកនាំមួយចំនួន បានដើរពិនិត្យមើលដោយផ្ទាល់នូវសមិទ្ធផលសម្រេចបានរបស់អ.វ.ត.ក. ទាំងនៅក្នុងដំណាក់កាលជំនុំជម្រះក្តីអស់រយៈពេល ១៦ឆ្នាំ (២០០៦-២០២២) និងទាំងក្នុងកំលុងពេលកំពុងអនុវត្តមុខងារសេសសល់ចាប់ពីឆ្នាំ ២០២៣មក។ ជាពិសេស ការបង្កើតឱ្យមាន «**មជ្ឈមណ្ឌលធនធានរបស់ អ.វ.ត.ក.**» ដែលមានសមាសភាគសំខាន់ៗចំនួន៦ ដូចដែលបានលើកឡើងដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ រួចហើយដែរ។

ក្រៅពីសមិទ្ធផលខាងលើ ខ្ញុំក៏សូមគូសបញ្ជាក់អំពីសារៈសំខាន់នៃការបន្តអប់រំ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីបណ្ណសារនៃសំណុំរឿង និងសមិទ្ធផលការងារសម្រេចបានរបស់ អ.វ.ត.ក. ដើម្បីឱ្យសិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវជាតិ-អន្តរជាតិ អាចមានលទ្ធភាពពង្រីកចំណេះដឹងរបស់ពួកគេពាក់ព័ន្ធនឹងរបបខ្មែរ។ ជាមួយគ្នានេះ យើងត្រូវជម្រុញឱ្យមានសហថាមភាពក្នុងចំណោមក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័ន អប់រំ វប្បធម៌ យុត្តិធម៌ និងទេសចរណ៍ ក្នុងការផ្ទេរនិងទទួលចំណេះដឹង ចំណេះធ្វើ បទពិសោធ ល្អៗ និងឯកសារនានាពីអ.វ.ត.ក. ក្នុងស្មារតីបញ្ជ្រាបការយល់ដឹង និងការចូលរួមថែរក្សាសមិទ្ធផលទាំងនេះសម្រាប់មនុស្សជំនាន់ក្រោយ ព្រមទាំងបង្ការនិងទប់ស្កាត់អំពើជ្រុលនិយម និងការកើតឡើងវិញនៃអតីតកាលដ៏ខ្មៅងងឹតនិងដ៏ជូរចត់របស់កម្ពុជានាពេលអនាគត។

ជាមួយនឹងការអប់រំ និងការផ្សព្វផ្សាយអំពីសមិទ្ធផលរបស់ អ.វ.ត.ក. នេះ យើងក៏ត្រូវគិតគូរផងដែរ អំពីការថែរក្សាប្រកបដោយលក្ខណៈនិរន្តរភាពនូវសមិទ្ធផលគម្រោងសំណងសមូហភាពនិងផ្លូវចិត្ត ដែលអ.វ.ត.ក. បានសម្រេចផ្តល់ឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះនៃរបបខ្មែរក្រហម នាពេលកន្លងមក និងបង្កើតគម្រោងនានាបន្ថែមទៀត ដើម្បីបន្តផ្តល់ការគាំទ្រដល់ដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះទាំងអស់។

*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

សមិទ្ធផលដ៏ថ្លៃថ្លាជាប្រវត្តិសាស្ត្ររបស់អ.វ.ត.ក. ដូចដែលយើងបានឃើញនៅពេលនេះ បានធ្វើឱ្យប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថាជាប្រទេសមួយ ដែលមានសក្តានុពលជាងគេក្នុងតំបន់ទាក់ទងទៅនឹងការកសាងសន្តិភាព ការបង្រួបបង្រួមជាតិ ការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងដំណើរការទទួលខុសត្រូវចំពោះមុខច្បាប់ (Accountability Process)។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានផ្តល់គោលការណ៍បង្កើត **«វិទ្យាស្ថានរបស់រដ្ឋមួយទទួលបន្ទុកកេរដំណែលរបស់ អ.វ.ត.ក.»** ដើម្បីចងក្រង គ្រប់គ្រងឯកសារ និងជាមណ្ឌលស្រាវជ្រាវ ចែករំលែកចំណេះដឹង និងផ្តល់ព័ត៌មានដល់អ្នកជំនាន់ក្រោយ អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទូទៅ ដើម្បីស្វែងយល់បន្ថែមអំពីអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ក៏ដូចជាជោគជ័យនៃដំណើរការជំនុំជម្រះក្តីរបស់ អ.វ.ត.ក.។

*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ជាមួយគ្នានេះដែរ, ខ្ញុំក៏សូមស្នើឱ្យក្រុមការងាររាជរដ្ឋាភិបាល ទទួលបន្ទុកដំណើរការអនុវត្ត

មុខងារសេសសល់ និងរដ្ឋបាលនៃ អ.វ.ត.ក. ក៏បន្តការពិចារណាឱ្យបានស៊ីជម្រៅទៅលើចំណុចចំនួន៦ទៀត រួមមាន៖ ទី១-អំពីតួនាទី និងការទទួលខុសត្រូវស្នូលរបស់វិទ្យាស្ថាន (Core Roles and Responsibilities), ទី២-អំពីឈ្មោះនិងរចនាសម្ព័ន្ធ (Name and Structure), ទី៣. អំពីឋានៈនិងទម្រង់ (Status and Modality), ទី៤-អំពីដៃគូសហប្រតិបត្តិការ (Partners of Cooperation), ទី៥-អំពីការវាយតម្លៃផលប៉ះពាល់ (Impact Assessment), និងទី៦-អំពីតម្រូវការថវិកា (Budget Requirements)។

ជាទីបញ្ចប់ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមផ្តាំផ្ញើ តាមរយៈឯកឧត្តម **មីហ្គែល ឌឺ សែប៉ា សូអារ៉េស (Miguel de Serpa Soares)** អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងជាទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ ជូនទៅឯកឧត្តម **António Guterres** អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ នូវការកោតសរសើរ និងវាយតម្លៃខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការចូលរួមបង្កើតឱ្យមានតុលាការកូនកាត់គំរូមួយក្នុងទម្រង់ជា **«អ.វ.ត.ក. ឬសាលាក្តីខ្មែរក្រហម»** និងក៏សូមថ្លែងអំណរគុណដល់សហគមន៍អន្តរជាតិផងដែរ ដែលបានគាំទ្រទាំងផ្នែកនយោបាយ បច្ចេកទេស និងថវិកា ដែលអនុញ្ញាតឱ្យតុលាការនេះបានបញ្ចប់ទាំងស្រុងនូវដំណើរការកាត់សេចក្តីរបស់ខ្លួនប្រកបទៅដោយភាពរលូន ជោគជ័យ និងមានការទទួលស្គាល់ជាអន្តរជាតិ។ ជោគជ័យរបស់តុលាការនេះ ត្រូវបានចាត់ទុកជាជោគជ័យរួមទាំងអស់គ្នា រួមមាន៖ រាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ជាពិសេស គឺជាជោគជ័យសម្រាប់ជនរងគ្រោះនិងមនុស្សជាតិទាំងមូល។

ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលមានវត្តមាននៅទីនេះ ទទួលបាននូវសុខភាពល្អ, វិបុលភាព, សុភមង្គល និង ជោគជ័យក្នុងគ្រប់ភារកិច្ច។

**សូមអរគុណ !**